**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

នាយកដ្ឋានព័ត៌មាន

# សេចក្តីថ្លែងការណ៍
# របស់អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

******

ប៉ុន្មានសប្តាហ៍ថ្មីៗនេះ បុគ្គល សម រង្ស៊ី ដែលជាទណ្ឌិតជនជាតិខ្មែរមានសញ្ជាតិបរទេស បានធ្វើការអំពាវនាវឥតឈប់ឈរដល់សហគមន៍អន្តរជាតិ ឲ្យចោទសួរពីធម្មានុរូបភាពរបស់រាជរដ្ឋាភិបាលកម្ពុជា និងអំពាវនាវឲ្យកងយោធពលខេមរភូមិន្ទ និងប្រជាជន ងើបបះបោរប្រឆាំងរាជរដ្ឋាភិបាលដែលបានជាប់ឆ្នោតតាមលទ្ធិប្រជាធិបតេយ្យ ជាមួយនឹងសម្លេងឆ្នោតយ៉ាងច្រើនលើសលុបរបស់ម្ចាស់ឆ្នោត។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទង្វើរបស់ទណ្ឌិត សម រង្ស៊ី ដែលបានអំពាវនាវមិនឲ្យកងទ័ពស្តាប់បញ្ជានិងឲ្យមានការបះបោរ និងសេចក្តីថ្លែងការណ៍ដ៏ពិសពុលរបស់ជនរូបនេះ។ ក្នុងការអះអាងដែលគ្មានមូលដ្ឋានថា ការបោះឆ្នោតជាសកលកាលពីខែ កក្កដា ឆ្នាំ ២០១៨ មិនមានធម្មានុរូបភាព បុគ្គលរូបនេះបានប្រើប្រាស់វោហាសាស្ត្រនយោបាយដដែលៗ ចំពោះរាល់ការបោះឆ្នោតថ្នាក់ជាតិ ចាប់តាំងពីឆ្នាំ១៩៩៨ មក ដែលបុគ្គលនេះ និងគណបក្សដែលគាត់ដឹកនាំ បានទទួលបរាជ័យរហូតមក។ នៅពេលដែលទណ្ឌិត សម រង្ស៊ី អួតអាងខ្លួនឯងថាជាវីរៈបុរស និងទុក្ករបុគ្គលនៃលទ្ធិប្រជាធិបតេយ្យនោះ នៅក្នុងបណ្តាប្រទេសអឺរ៉ុប និងអាស៊ីប្រទេសធំៗផ្សេងទៀត បុគ្គលរូបនេះគួរត្រូវបានចាត់ទុកជាជនប្រជាភិថុតិ ជនប្រជាកលនិយមប្រកបដោយគ្រោះថ្នាក់ ជាតិនិយមហួសហេតុ និងប្រកាន់ពូជសាសន៍ ដែលដើរឃោសនាឲ្យមានការបែកបាក់ក្នុងសង្គម និងការផ្លាស់ប្តូររបបដោយមធ្យោបាយហិង្សា។ អ្នកបោះឆ្នោតកម្ពុជាបានបដិសេធដាច់អហង្ការនូវគោលបំណងទុច្ចរិតនេះ និងបានជ្រើសរើសមាគ៌ាប្រជាធិបតេយ្យ តាមរយៈដំណើរការបោះឆ្នោត។

សេចក្តីថ្លែងការណ៍របស់បុគ្គលរូបនេះ មិនត្រឹមតែមើលស្រាលយ៉ាងធ្ងន់ធ្ងរដល់គណបក្សនយោបាយចំនួន១៩ទៀត ដែលបានចូលរួមបោះឆ្នោតប៉ុណ្ណោះទេ តែថែមទាំងមើលស្រាលដល់ឆន្ទៈ

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ម្ចាស់ឆ្នោតប្រមាណ ៨៣,២% ដែលបានបោះឆ្នោតគាំទ្រដល់គណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាចដោយសំលេងភាគច្រើនលើសលុប។ កំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លាក្នុងអត្រា៧,៧% ក្នុងរយៈកាលជាងពីរទស្សវត្សរ៍ រួមជាមួយនឹងស្ថិរភាពនយោបាយ ការបែងចែកផ្លែផ្កានៃវិបុលភាពប្រកបដោយសមធម៌ គឺជាមូលដ្ឋានពន្យល់យ៉ាងច្បាស់នូវជម្រើសដ៏ឧត្តុង្គឧត្តមរបស់ប្រជាជនកម្ពុជា ដែលប្រាថ្នាចង់បានមាគ៌ាជាបន្តប្រកបដោយសន្តិភាព និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ ការអំពាវនាវទាំងនេះ គឺគ្រាន់តែជាការអុចអាល និងញុះញង់ ដើម្បីតែមហិច្ឆតាចង់បានអំណាចរបស់ទណ្ឌិតរូបនេះតែប៉ុណ្ណោះ។ រាជរដ្ឋាភិបាលនឹងប្រឆាំងទប់ស្កាត់តាមគ្រប់មធ្យោបាយ ចំពោះរាល់ការប៉ុនប៉ងនានា និងការធ្វើអន្តរាគមន៍ពីភាគីទី៣ ក្នុងការបង្កអស្ថិរភាព និងបំផ្លិចបំផ្លាញមាតុភូមិ ក៏ដូចជាសុភមង្គលរបស់ប្រជាជនយើង។ យើងនឹងការពារប្រជាជាតិយើង ប្រឆាំងទល់នឹងកលល្បិចទាំងនេះ ទោះក្នុងតម្លៃណាក៏ដោយ។

រាជរដ្ឋាភិបាលត្រូវបានជាប់ឆ្នោតដោយត្រឹមត្រូវ បង្កើតឡើងដោយស្របច្បាប់ និងត្រូវបានទទួលស្គាល់ជាផ្លូវការដោយបណ្តាប្រទេសជាច្រើន រួមទាំងប្រទេសនានានៅក្នុងសហភាពអឺរ៉ុប និងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យសំខាន់ៗផ្សេងៗទៀត។

ព្រះរាជាណាចក្រកម្ពុជារីករាយជាមួយនឹងចំណងមិត្តភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើរជាមួយប្រទេសទាំងអស់នៅលើពិភពលោក។ នៅក្នុងស្មារតីនេះហើយដែលយើងបានអំពាវនាវមិនឲ្យមានការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង និងឲ្យមានការគោរពអធិបតេយ្យភាពរបស់កម្ពុជា ដើម្បីឲ្យកម្ពុជាអាចបន្តដំណើរលើមាគ៌ារបស់ខ្លួនឆ្ពោះទៅរកសាមគ្គីភាពជាតិ ការពង្រឹងថែមទៀតនូវលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការលើកកម្ពស់សិទ្ធិមនុស្ស និងនីតិរដ្ឋ ដើម្បីថែរក្សាសន្តិភាព ស្ថិរភាព ឯកភាពជាតិ និងសណ្តាប់ធ្នាប់សាធារណៈ។៸

ថ្ងៃសៅរ៍ ៥កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៩